

កម្មវិធី ១_៣
ត្រូវឲ្យទទួលស្គាល់ទ្រង់



(3)

នេះគឺជាពាក្យរបស់លោក ដេ រិក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

> ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ
> នោះទ្រង់នឹងតម្រង់អស់ទាំងផ្លូវច្រករបស់ឯង។ [សុភាសិត ៣:៦]

តើអ្នកចង់បានការធានាថាព្រះជាម្ចាស់កំពុងតែគ្រប់គ្រងផ្លូវរបស់អ្នក
ជីវិតរបស់អ្នក ដែលទ្រង់កំពុងដឹកនាំ
ដែលទ្រង់កំពុងតែណែនាំនៅក្នុងការសម្រេចចិត្តរបស់អ្នក
ហើយត្រៀមខ្លួនដើម្បីដោះស្រាយបញ្ហារបស់អ្នកឬទេ?

ព្រះបន្ទូលដែលខ្ញុំបានអាននេះគឺជាគន្លឹះនៃការធានានោះ។
«ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ»
នេះហើយគឺជាព្រះអម្ចាស់។ នៅរាល់ពេលផ្ទាក រាល់ចំណុចរបត់
រាល់ពេលដែលអ្នកអាចសម្រាក និងដកដង្ហើមបានមួយភ្លែត
ហើយអ្នកមិនត្រូវបានគេទទូចឲ្យធ្វើការសម្រេចចិត្តពិសេសមួយចំនួន
ទេ ចូរទទួលស្គាល់ទ្រង់។
វិធីដ៏ល្អបំផុតក្នុងការទទួលស្គាល់ទ្រង់គឺគ្រាន់តែជាការអរព្រះគុណដ
ល់ទ្រង់ប៉ុណ្ណោះ។

អរព្រះគុណព្រះអង្គដែលទ្រង់ជាអ្នកទទួលខុសត្រូវ។

សូមអរព្រះគុណព្រះអង្គចំពោះភាពស្មោះត្រង់របស់ទ្រង់។

អរព្រះគុណទ្រង់ចំពោះជំនួយទាំងអស់
ដែលអ្នកបានទទួលពីទ្រង់កាលពីអតីតកាល។
សូមអរព្រះគុណទ្រង់ចំពោះប្រាជ្ញារបស់ទ្រង់។
អរព្រះគុណទ្រង់ចំពោះអំណាចចេស្តារបស់ទ្រង់។
នៅពេលអ្នកអរព្រះគុណទ្រង់ អ្នកកំពុងទទួលស្គាល់ទ្រង់ហើយ។
អ្នកកំពុងអនុញ្ញាតឲ្យទ្រង់គ្រប់គ្រងលើជីវិត និងស្ថានភាពរបស់អ្នក
ហើយតាមរបៀបនេះឯងដែលអ្នកនៅតែបន្តមានការដឹកនាំ
និងការណែនាំពីទ្រង់។
ចូរទទួលស្គាល់ទ្រង់រាល់ពេលទាំងអស់ដោយការអធិស្ឋានយ៉ាងខ្លីថា៖
«សូមអរព្រះគុណព្រះអម្ចាស់។
សូមអរព្រះគុណព្រះអង្គដែលទ្រង់ទទួលបន្ទុកលើស្ថានភាពនេះ។

សូមអរព្រះគុណព្រះអង្គដែលទ្រង់មានចម្លើយចំពោះបញ្ហានេះ។
នៅគ្រប់ជំហាន ព្រះអម្ចាស់អើយ ទូលបង្គំសូមទទួលស្គាល់ទ្រង់។
រាល់សំណូរទូលបង្គំនាំយកថ្វាយព្រះអង្គ។
រាល់ការសម្រេចចិត្តទាំងអស់ទូលបង្គំថ្វាយដល់ទ្រង់សម្រេច។

© 1970 — Derek Prince Ministries - International®

សូមអរព្រះគុណព្រះអម្ចាស់
ដែលទ្រង់ជាអ្នកទទួលខុសត្រូវលើបន្ទុកនេះ។

សូមអរព្រះគុណព្រះអង្គដែលទ្រង់មានឆន្ទៈទទួលយកការទទួលខុស
ត្រូវនេះ»។ នៅពេលអ្នកទទួលស្គាល់ទ្រង់នៅគ្រប់ជំហានដូច្នេះ
អ្នកអាចប្រាកដថា ទ្រង់ពិតជានឹងដឹកនាំផ្លូវអ្នក។

: WD-WFTW-003-KHM
: 24 Feb 2026
: derekprince.com/km/resources

